## តើអ្វីទៅជាភ្នាក់ងារប្រមែប្រមូល?

**ភ្នាក់ងារប្រមែប្រមូល**មួយជំនាញនៅក្នុងការប្រមែប្រមូលការបង់ប្រាក់ដែលហួសកំណត់ ។ ភ្នាក់ងារប្រមែប្រមូល អាច-បំផ្លាញការផ្តល់ចំណាត់ថ្នាក់កិត្តិយសរបស់លោកអ្នក និងទទួលបានដីកាតុលាការដើម្បី:

- យករាល់ការបង់ប្រាក់ដោយផ្ទាល់ពីមូលប្បទានប័ត្របង់ប្រាក់បៀវត្សន៍របស់លោកអ្នក ។
- ដាក់សិទ្ធិយកទ្រព្យរបស់កូនបំណុលនៅលើលំនៅដ្ឋានរបស់លោកអ្នក ដែលមានន័យថាប្រសិនបើលោកអ្នកលក់លំនៅដ្ឋានរបស់លោកអ្នក ភ្នាក់ងារនេះប្រមូលការបង់ប្រាក់ចេញពីប្រាក់ចំណេញដែលលោកអ្នកបានទទួលពីការលក់នេះ ។




California Public
Utilities Commission

**Telecommunications
Education and Assistance
in Multiple-Languages
(TEAM) Program**

www.cpuc.ca.gov/team-and-changes

cabteamandchanges@cpuc.ca.gov

If you are not able to resolve
your dispute with your service provider,
call the Consumer Affairs Branch
(800) 649-7570

# ភ្នាក់ងារប្រមែប្រមូល - អ្វីដែលត្រូវធ្វើ

គណៈកម្មការ
សេវាកម្មសាធារណៈ
ប្រចាំរដ្ឋកាលីហ្វ័រញ៉ា





## ក្រុមហ៊ុនទូរស័ព្ទអាចផ្ញើរវិក្ក័យប័ត្រមិនទាន់បង់ទៅកាន់ភ្នាក់ងារប្រមែប្រមូល

ជាទូទៅ ក្រុមហ៊ុនទូរស័ព្ទនឹងផ្តាច់សេវាកម្មមួយចំនួន ឬទាំងអស់នៃសេវាកម្មរបស់លោកអ្នកដោយមិនបង់ប្រាក់មុនពេលពួកគេផ្ញើរវិក្ក័យប័ត្ររបស់លោកអ្នកទៅឱ្យភ្នាក់ងារប្រមែប្រមូល បើពុំនោះទេលុះត្រាតែលោកអ្នកកំពុងមានជម្លោះពីវិក្ក័យប័ត្រនេះ។ ក្រុមហ៊ុនទូរស័ព្ទនៅរដ្ឋកាលីហ្វ័រញ៉ា មិនអាចផ្ញើរវិក្ក័យប័ត្រមួយទៅឱ្យភ្នាក់ងារប្រមែប្រមូលទេ នៅពេលដែលពួកគេកំពុងដោះស្រាយជម្លោះរបស់លោកអ្នក។

*គេចពីភ្នាក់ងារប្រមែប្រមូលដោយបង់វិក្ក័យប័ត្រទាំងស្រុងរបស់លោកអ្នកជារៀងរាល់ខែ ឬវិក្ក័យប័ត្រចុងក្រោយរបស់លោកអ្នកឆាប់ៗបន្ទាប់ពីទទួលបានវា។*

# *ភ្នាក់ងារប្រមែប្រមូល – អ្វីដែលត្រូវធ្វើ*

នៅក្នុងអំឡុងពេលប្រាំថ្ងៃរបស់ភ្នាក់ងារប្រមែប្រមូលទំនាក់ទំនងលោកអ្នកអំពីវិក្ក័យប័ត្រដែលមិនទាន់បង់ ភ្នាក់ងារនេះត្រូវតែប្រាប់លោកអ្នកអំពីៈ

- ចំនួនទឹកប្រាក់ដែលលោកអ្នកជំពាក់
- តើលោកអ្នកជំពាក់អ្នកណា
- របៀបបង្កជម្លោះស្តីពីវិក្ក័យប័ត្រ
- ឈ្មោះ អាសយដ្ឋាន និងលេខទូរស័ព្ទរបស់ភ្នាក់ងារប្រមែប្រមូល
- កាលបរិច្ឆេទនៃសេចក្តីជូនដំណឹងដែលបានផ្ញើរទៅលោកអ្នក

### តើខ្ញុំអាចធ្វើអ្វីខ្លះ ក្រោយពេលដែលខ្ញុំទទួលបានលិខិតពីភ្នាក់ងារប្រមែប្រមូល?

1) ត្រូវបង់វិក្ក័យប័ត្រដោយផ្ទាល់ទៅឱ្យភ្នាក់ងារប្រមែប្រមូល។ លោកអ្នកអាចពិភាក្សាពីផែនការបង់ប្រាក់ ប្រសិនបើលោកអ្នកមិនអាចបង់ប្រាក់វិក្ក័យប័ត្រទាំងមូលតែមួយលើកបាន។ មិនត្រូវហៅទូរស័ព្ទ ឬផ្ញើរប្រាក់ទៅឱ្យក្រុមហ៊ុនទូរស័ព្ទឡើយ។

2. ឈ្លោះស្តីពីវិក្ក័យប័ត្រដោយផ្ទាល់ជាមួយភ្នាក់ងារប្រមែប្រមូល ប្រសិនបើលោកអ្នកមិនយល់ស្របជាមួយការគិតកំរៃ។ នៅពេលដែលភ្នាក់ងារប្រមែប្រមូលដឹងថាលោកអ្នកកំពុងមានជម្លោះពីកំរៃ ពួកគេត្រូវតែស៊ើបអង្កេតពីបណ្តឹងរបស់លោកអ្នក។ ពួកគេប្រហែលជាអាចមិនមានចេតនាប្រមូលបំណុលនេះរហូតដល់ពេលដែលការស៊ើបអង្កេតគឺចប់រួចរាល់។
3. បដិសេធសងបំណុលនេះ។ ប្រសិនបើលោកអ្នកបដិសេធសងបំណុលនេះ ហើយចង់ឱ្យភ្នាក់ងារនេះឈប់ទូរស័ព្ទទៅអ្នក ត្រូវផ្ញើរលិខិតធ្វើការជូនដំណឹងដល់ពួកគេមិនឱ្យទាក់ទងលោកអ្នក។ បន្ទាប់ពីទទួលបានលិខិតនោះ ភ្នាក់ងារនេះនឹងទំនាក់ទំនងលោកអ្នកម្តងទៀត ដើម្បីប្រាប់លោកអ្នកពីវិធានការដែលអាចមានចំពោះលោកអ្នក។







ចងចាំថាត្រូវកត់ត្រាពីអ្វីដែលលោកអ្នក និងភ្នាក់ងារប្រមែប្រមូលដែលបានពិភាក្សា ធ្វើការថតចម្លងនូវអ្វីៗដែលលោកអ្នកសរសេរសំបុត្រទៅកាន់ភ្នាក់ងារនេះ នៅពេលដែលវិក្ក័យប័ត្ររបស់លោកអ្នកត្រូវបានបង់ ស្នើសុំភ្នាក់ងារនេះបញ្ជូនឱ្យលោកអ្នកនូវការបញ្ជាក់ (លោកអ្នកអាចត្រូវការការបញ្ជាក់មួយ ដើម្បីលុបការចាត់ថ្នាក់កិត្តិយសរបស់លោកអ្នក)។